00163166

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C11/29

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០១)

# អង្គបុរេជំនុំជម្រះ

នៅចំពោះមុខ:

ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ម៉ែន ពេជ្រសាលី
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / FEB / 2008
ម៉ោង (Time/Heure): 10:00'
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNVICHET

ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨

---

## សេចក្តីសម្រេចជាសាធារណៈ: ស្តីពីបណ្តឹងជំទាស់ចិត្តជាបន្ទាន់របស់សហមេធាវី ជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម នៃយ ថុល

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 02 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA KOSAL

**សហព្រះរាជអាជ្ញា៖**
ជា លាង
Robert PETIT

**ជនត្រូវចោទ**
នួន ជា

**មេធាវីការពារក្តី៖**
លោក សុន អរុណ
លោក Michiel PESTMAN

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00163167

C11/29

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០១)

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

**បានឃើញ** បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ និងសារណារបស់សហមេធាវីចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ និងសេចក្តីសម្រេចកំណត់ពេលសវនាការលើបណ្តឹងឧទ្ធរណ៍នេះ ដែលនឹងត្រូវធ្វើឡើងនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ។

**បានឃើញ** បណ្តឹងជំទាស់ដោយផ្ទាល់មេធាវីចំពោះលោកចៅក្រម **នំយ ធុល** ដែលបានដាក់ជូនមកនៅ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ដោយអនុលោមតាមវិធាន៣៤ នៃវិធានផ្ទៃក្នុង។

**បានឃើញ** ការសង្កេតបឋមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ ទៅលើបណ្តឹងជំទាស់ដោយផ្ទាល់របស់ នួន ជា ចំពោះចៅក្រម **នំយ ធុល** ។

**បានឃើញ** ចម្លើយតបរបស់មេធាវី ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ ទៅនឹងការសង្កេតបឋមរបស់សហព្រះរាជអាជ្ញាលើបណ្តឹងជំទាស់ដោយផ្ទាល់ចំពោះចៅក្រម **នំយ ធុល** ។

**បានឃើញ** សារណាសម្ងាត់របស់ចៅក្រម **នំយ ធុល** ចុះនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០០៨ ដោយអនុលោមតាមវិធាន៣៤(៧) នៃវិធានផ្ទៃក្នុង ។

**យល់ឃើញថា** ចៅក្រម **នំយ ធុល** ពុំបានសម្រេចធ្វើការដកខ្លួនដោយស្ម័គ្រចិត្តឡើយ។

## I. ការសង្កេតបឋម

១. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ មេធាវីការពារក្តីបានព្យាយាមដាក់ពាក្យបណ្តឹងជំទាស់ដោយផ្ទាល់របស់ខ្លួនចំពោះចៅក្រម **នំយ ធុល** ។ ប៉ុន្តែបណ្តឹងនេះត្រូវបានបញ្ជូនត្រឡប់វិញ ដោយសារពុំបានបំពេញតាមលក្ខខណ្ឌនានា ដូចដែលមានចែងក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ នៅចំពោះមុខ អ.វ.ត.ក ។ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ សហមេធាវីបានដាក់ពាក្យបណ្តឹងរបស់ខ្លួនមកដោយគោរពតាមសេចក្តីណែនាំអនុវត្ត។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

២

00163168

C11/29



២. អង្គបុរេជំនុំជម្រះ កត់សំគាល់ឃើញថា ពាក្យបណ្តឹងដែលដាក់មកនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ មានហត្ថលេខារបស់លោក Victor Koppe តែម្នាក់ឯងក្នុងនាម លោកMichiel Pestman។ លើសពីនេះទៅទៀត អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា លោកVictor Koppe ពុំទាន់ត្រូវបានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឡើយ ។

៣. វិធាន៣៤(២)នៃវិធានផ្ទៃក្នុងចែងថា ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះចៅក្រមណាម្នាក់បាន(...) ។ កថាខណ្ឌ(៣) ចែងថា ពាក្យបណ្តឹងបែបនេះ ត្រូវបង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុ និងត្រូវមានបញ្ជាក់ភស្តុតាងផងដែរ ។ ពាក្យបណ្តឹងនេះត្រូវធ្វើឡើងឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅពេលភាគីបានដឹងអំពីមូលហេតុនៃបណ្តឹងជំទាស់នោះ។

៤. អង្គបុរេជំនុំជម្រះ សង្កេតឃើញថា ភស្តុតាងដែលបានលើកឡើងក្នុងនាមជនត្រូវចោទនោះគឺបានមកមុនពេលការចាប់ខ្លួនគាត់ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ។ ហេតុដូច្នេះ អង្គជំនុំជម្រះ លើកយកមកពិចារណាអំពីលក្ខខ័ណ្ឌដែលត្រូវគោរពតាម ដូចមានចែងក្នុងវិធាន ៣៤(៣) ដែលថា បណ្តឹងជំទាស់គួរធ្វើឡើងឱ្យបានឆាប់បំផុត “នៅពេលភាគីដឹងពីមូលហេតុនៃបណ្តឹងជំទាស់នោះ”។

៥. យោងតាមវិធាន៣៤(៥) នៃវិធានផ្ទៃក្នុង ចៅក្រមដែលកំពុងចោទជាបញ្ហាអាចចូលរួមបន្តនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ដោយរងចាំសេចក្តីសម្រេចស្តីពីបណ្តឹងជំទាស់នោះ។ កថាខណ្ឌ(៧) ចែងថា ចៅក្រមនៃអង្គជំនុំជម្រះ និងធ្វើការពិចារណាលើបណ្តឹងជំទាស់ចៅក្រម ជាមួយនឹងសារណារបស់ចៅក្រមដែលត្រូវគេប្តឹងជំទាស់ ហើយនិងត្រូវធ្វើការបោះឆ្នោតលើបញ្ហានេះ ។

៦. “សហព្រះរាជអាជ្ញាបានលើកឡើងថាមានមូលដ្ឋានតិចតួចណាស់សំរាប់ភាពបន្ទាន់នៃសំណើនេះ ។ យោងទៅតាមសារណាតបរបស់សហព្រះរាជអាជ្ញា ពេលវេលានៃការដាក់ឯកសារ និងការបរិច្ឆេទឲ្យឆ្លើយតបមិននាំឲ្យមានការគ្រប់គ្រងយុត្តិធម៌ត្រឹមត្រូវនោះទេ ហើយក៏មិនមានចេតនាពិតប្រាកដក្នុងការដោះស្រាយបញ្ហាបែបនេះដែរ ។ សំណើនេះគួរតែត្រូវបានដោះស្រាយឲ្យបានសមស្របដោយ អង្គបុរេជំនុំជម្រះ ដោយយកចិត្តទុកដាក់ត្រឹមត្រូវទៅលើឱកាសសម្រាប់គូភាគីដែលពាក់ព័ន្ធ ធ្វើការឆ្លើយតប

00163169

C11/29



យ៉ាងពេញលេញទៅនឹងមូលដ្ឋាននៃអង្គច្បាប់ និងអង្គហេតុនៃសំណើនេះ"។[១]

៧. មេធាវីលើកឡើងក្នុងចម្លើយតបរបស់ខ្លួន តបទៅនឹងការសង្កេតបឋមរបស់សហព្រះរាជអាជ្ញាថា "មេធាវីយល់ស្របទាំងស្រុងជាមួយនឹងសេចក្តីសន្និដ្ឋានរបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលថា "វាមិនចាំបាច់ទេក្នុងការសម្រេចទៅលើសំណើនេះមុនពេលសវនាការលើបណ្តឹងឧទ្ធរណ៍" ហើយស្នើជាយោបល់ថា សំរាប់ការដកខ្លួនដោយស្ម័គ្រចិត្តរបស់ចៅក្រម **ន័យ ធុល** **"ជាការបង្ហាញឱ្យឃើញនូវសកម្មភាពដ៏ត្រឹមត្រូវបំផុត"** ។ មេធាវីក៏បានស្នើផងដែរដល់អង្គបុរេជំនុំជម្រះឱ្យអញ្ជើញបណ្តាអង្គការ និងសាធារណជនឱ្យដាក់សារណាក្នុងរឿងនេះ និងធ្វើការរៀបចំសវនាការជាសាធារណៈ។

**ការយល់ឃើញជាបឋម**

៨. អង្គបុរេជំនុំជម្រះយល់ឃើញថាវិធាន៣៤ មានចែងអំពីនីតិវិធីមួយចំនួនដែលផ្តល់លទ្ធភាព ក្នុងការធ្វើការសម្រេចលើបណ្តឹងជំទាស់ ។ ក្នុងករណីនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា មានព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើការសម្រេចលើពាក្យបណ្តឹងនេះ ហើយដើម្បីផលប្រយោជន៍យុត្តិធម៌ ក្នុងការបន្តកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័ស អង្គបុរេជំនុំជម្រះធ្វើការវិនិច្ឆ័យលើបញ្ហានេះ ដោយមិនចាំបាច់បើកសវនាការជាសាធារណៈ និងស្វែងរកសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីឡើយ ។ លើសពីនេះទៅទៀត ដើម្បីផលប្រយោជន៍យុត្តិធម៌ អង្គបុរេជំនុំជម្រះនឹងមិនធ្វើការត្រួតពិនិត្យទៅលើបញ្ហាកំហុសបច្ចេកទេសដែលអាចកើតមាននៅក្នុងពាក្យបណ្តឹងនោះផ្ទាល់ទេ។

## II. **ការទទួលយកពាក្យបណ្តឹង**

៩. ពាក្យបណ្តឹងជំទាស់ស្នើដល់អង្គបុរេជំនុំជម្រះឱ្យដកលោកចៅក្រម **ន័យ ធុល** ពីគ្រប់កិច្ចដំណើរការទាំងអស់នាពេលខាងមុខ។[២] សមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះ ត្រូវបានកំណត់ក្នុងវិធាន ៣៤.២ នៃវិធានផ្ទៃក្នុង ដែលចែងថា:

---

[១] ការសង្កេតបឋមរបស់សហព្រះរាជអាជ្ញាលើបណ្តឹងជំទាស់បន្ទាន់របស់ខ្លួន ជា ចំពោះចៅក្រម ន័យ ធុល ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨កថាខណ្ឌ៩។

[២] អានពាក្យបណ្តឹងជំទាស់ កថាខ័ណ្ឌ១ និង ៤៩

* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC ៤

00163170

C11/29



"ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះចៅក្រម ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឱ្យមានភាពលំអៀង"។

១០. នេះមានន័យថា អង្គបុរេជំនុំជម្រះមានយុត្តាធិការសម្រេចលើពាក្យបណ្តឹងជំទាស់ ក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នលោក នួន ជា ។ ដូច្នេះ ពាក្យបណ្តឹងដែលបានដាក់មកដំបូងមិនត្រូវបានទទួលយកទេដោយហេតុថាពាក្យបណ្តឹងនោះស្នើសុំឱ្យចេញដីកាសម្រេច លើករណីទូទៅ សម្រាប់បណ្តឹងជំទាស់ ។ មេធាវីបានព្យាយាមកែតម្រូវបញ្ហានេះ ក្នុងសារណាតបទៅនឹងការសង្កេតបឋមរបស់សហព្រះរាជអាជ្ញា។

១១. អង្គបុរេជំនុំជម្រះ យល់ថាពាក្យបណ្តឹងនេះអាចទទួលយកបាន ដោយហេតុថាពាក្យបណ្តឹងនេះប្តឹងជំទាស់លោកចៅក្រម **ន៉យ ថុល** តែពីក្នុងកិច្ចដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឡើងដោយលោក នួន ជា ប៉ុណ្ណោះ។

## III. **ការវាយតម្លៃទៅលើភាពលំអៀង**

១២. ការវាយតម្លៃលើភាពលំអៀងដែលធ្វើឡើងដោយអង្គបុរេជំនុំជម្រះ គឺមានចែងក្នុងវិធាន៣៤.២ ដូចបានរៀបរាប់ខាងលើ និងសំដៅទៅលើភាពលំអៀងដែលជាសកម្មភាពពិតប្រាកដ និងភាពលំអៀងដែលមើលឃើញពីខាងក្រៅ។

១៣. មេធាវីការពារក្តីស្នើឡើងថា "មេធាវីមិនបានដឹងអំពីភស្តុតាងណាមួយអំពីភាពលំអៀងដោយសកម្មភាពពិតប្រាកដរបស់លោកចៅក្រម **ន៉យ ថុល** ដែលប្រឆាំងនឹងលោក នួន ជា ឬខ្មែរក្រហមទេ។ លើសពីនេះទៅទៀត ពាក្យបណ្តឹងបច្ចុប្បន្ននេះ មិនបានចោទប្រកាន់អំពីផលប្រយោជន៍ផ្នែកបុគ្គល ឬផ្នែកហិរញ្ញវត្ថុណាមួយដែលជាលទ្ធផលពីកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក" ឡើយ។ ជាមួយគ្នានេះផងដែរ មេធាវីមិនបានស្វែងរកការវាយតម្លៃលើភាពអត្តនោម័ត ឬការវាយតម្លៃជាលើកដំបូងលើភាព

សន្យានុម័ត ដូចបានលើកឡើងក្នុងសេចក្ដីសម្រេចរឿងក្ដីរបស់ ហ្វូរ៉ាន់ហ្ស៊ីហ្យា (Furundzija) និងក្នុងដូចដែលបានបង្ហាញក្នុងវិធាន៣៤.២"។[៣]

១៤. មេធាវីបានលើកឡើងក្នុងបន្តទៀតក្នុងពាក្យបណ្ដឹងរបស់ខ្លួនក្នុងកថាខ័ណ្ឌ ២៤ ថា: ពាក្យបណ្ដឹងមានពីរចំណុចសំខាន់គឺ (១) ឋានៈរបស់លោកចៅក្រម **នីយ ធុល** ជាមន្ត្រីនៅក្នុងកងយុទ្ធពលខេមរៈភូមិន្ទ ដែលក្លាយទៅជាការចូលរួមមួយដែលអាចប៉ះពាល់ដល់ភាពអនាគតិរបស់គាត់[...] យ៉ាងពិតប្រាកដ និង(២) ការសម្ដែងនូវឆន្ទៈរបស់គាត់ដែលបង្ហាញឱ្យឃើញអំពីការប្រើអំណាចតុលាការមិនសមរម្យ ដោយតាមការបង្គាប់របស់គណបក្សប្រជាជន គឺ"ពិតជាបង្ហាញឱ្យឃើញនូវភាពលំអៀងដែលមើលឃើញពីខាងក្រៅ"។ ម្យ៉ាងវិញទៀត មុខតំណែងលោកចៅក្រម **នីយ** ជាមន្ត្រី យោធា និងការចូលរួមរបស់គាត់ក្នុងការសម្រេចសេចក្ដីរបស់តុលាការដែលជាបញ្ហាដ៏សំខាន់ នឹងនាំឱ្យមានការកត់សំគាល់សមហេតុផល និងព័ត៌មានត្រឹមត្រូវយល់ថា មានការលំអៀងដ៏សមហេតុផល ប្រឆាំងនឹងលោក នួន ជា និងខ្មែរក្រហម និងដើម្បីផ្គាប់ចិត្តគណបក្សប្រជាជន។

១៥. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា "ចំណុចចាប់ផ្ដើមនៃការសម្រេចលើការជំទាស់អំពី [ភាពលំអៀង] គឺថា "មានការសន្មតទុកជាមុនអំពីភាពមិនលំអៀងដែលមានចំពោះចៅក្រម"[៤] "ការសន្មតនេះ កើតចេញពីការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សំរាប់ការតែងតាំងរបស់គាត់[...]" និងដាក់បន្ទុកដ៏ធ្ងន់ចំពោះភាគីដែលធ្វើបណ្ដឹងជិតចិត្តក្នុងការដកចេញនូវការសន្មតទុកជាមុននេះ"[៥] ។

១៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ការសន្មត់អំពីភាពអនាគតិនេះគឺអនុវត្តចំពោះចៅក្រមទាំងអស់នៃ អ.វ.ត.ក។ មាត្រា៣.៣ នៃកិច្ចព្រមព្រៀងរវាងសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការ

---

[៣] អានពាក្យបណ្ដឹងជិតចិត្ត កថាខ័ណ្ឌ២៣

[៤] *ព្រះរាជអាជ្ញា v. Furundzija* IT-៩៥-១៧/១-A "សាលក្រម" អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ១៩៦។

[៥] *ព្រះរាជអាជ្ញា v. Karemera, Rwamajuba, Ngirumpatse, Nzirorera,* ICTR-98-44-T "សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្ត របស់ Karemera ចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ កថាខណ្ឌ១០។

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

00163172

C11/29



កាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ចែងថា:

> ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មាតីខ្ពស់ មិនលំអៀង និងសុច្ចរិតមានគុណសម្បត្តិដែលតម្រូវសម្រាប់តែងតាំងឲ្យបម្រើការងារក្នុងការិយាល័យតុលាការ នៅក្នុងប្រទេសរបស់ខ្លួន ។ ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ។

តាមមាត្រា៧.២ នៃកិច្ចព្រមព្រៀង បទប្បញ្ញត្តិនេះត្រូវអនុវត្តដោយស្មើភាពគ្នាចំពោះចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះ។

១៧. មាត្រា១០ថ្មីនៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ចែងថា"ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះវិសាមញ្ញត្រូវតែងតាំងចេញពីក្នុងចំណោមចៅក្រមដែលកំពុងបំពេញការងារបច្ចុប្បន្ន ឬ ទទួលការតែងតាំងបន្ថែមយោងតាមនីតិវិធីដែលមានស្រាប់សំរាប់ការតែងតាំងនេះ ចៅក្រមទាំងអស់ត្រូវមានចរិតលក្ខណៈសីលធម៌ខ្ពស់ ស្មារតីអនាគតិ ភាពសុច្ចរិត និងជាពិសេសមានបទពិសោធន៍ ក្នុងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិរួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផង។ ចៅក្រមទាំងអស់ ត្រូវស្ថិតនៅឯករាជ្យក្នុងការបំពេញមុខនាទីរបស់ខ្លួន និងមិនត្រូវទទួលយក ឬស្វែងរកការណែនាំណាមួយពីរដ្ឋាភិបាលណាមួយ ឬប្រភពណាមួយដទៃទៀតឡើយ"។

១៨. អង្គជំនុំជម្រះកត់សំគាល់បន្ថែមទៀតថា នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៦ ចៅក្រមនៃអង្គបុរេជំនុំជម្រះរបស់ អ.វ.ត.ក រួមទាំងចៅក្រម **នៃយ ថុល** ផងដែរ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និងបានធ្វើសច្ចាប្រណិធានជាផ្លូវការណ៍ ក្នុងពិធីផ្លូវការណ៍មួយ។[៦]

១៩. ក្នុងបញ្ហានេះ អ្នកប្តឹងជិតចិត្តត្រូវបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ដល់អង្គបុរេជំនុំជម្រះដើម្បីឲ្យអង្គបុរេជំនុំជម្រះយល់ឃើញថា ចៅក្រមដែលត្រូវបានប្តឹងចោទប្រកាន់នោះអាចមានភាពលំអៀងពិតប្រាកដមែន ។ គឺមាននៅមានចំណុចជាមូលដ្ឋានជាច្រើនដែលត្រូវបំពេញ ដើម្បីជំទាស់ទៅនឹងការសន្មតជាមុននៃភាពអនាគតិ។

[៦] ព្រះរាជក្រឹត្យចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៦ NS/RKT/0506/214

២០. យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ គឺមានលក្ខណៈដូចគ្នាក្នុងការធ្វើការវាយតម្លៃអំពីភាពលំអៀងដែលបានអនុវត្តក្នុងពេលនេះ។ សាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) បានយល់ឃើញ ក្នុងករណីរបស់ហ្វូរ៉ាន់ហ្សុីហ្សា (Furundzija)ថា:

> ចៅក្រមមួយរូបត្រូវបានចាត់ទុកថាមានភាពលំអៀង ប្រសិនបើត្រូវបានរកឃើញថាមានសកម្មភាពលំអៀងពិតប្រាកដមែន។
>
> មានការលំអៀងតាមរយៈការមើលឃើញពីខាងក្រៅ ប្រសិនបើ:
>
> - ចៅក្រមមួយរូបជាភាគីនៃរឿងក្តី ឬមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬទាក់ទងនឹងកម្មសិទ្ធ ដែលបានមកពីរឿងក្តីនោះ ឬ ប្រសិនបើការសម្រេចសេចក្តីរបស់ចៅក្រមនឹងនាំឲ្យ មានការគាំទ្រដល់រឿងក្តីមួយ ដែលរូបគាត់មានការពាក់ព័ន្ធជាមួយភាគីណាមួយនៃរឿងក្តីនោះ។ ក្នុងកាលៈទេសៈបែបនេះ ចៅក្រមរូបនោះ ត្រូវដកខ្លួនចេញពីរឿងក្តីនោះដោយស្វ័យប្រវត្តិ ឬ
> - ក្នុងកាលៈទេសៈដែលអាចនាំឲ្យមានការកត់សម្គាល់មួយដ៏សមហេតុផលមួយនិងមានព័ត៌មានត្រឹមត្រូវចំពោះការយល់ដឹងអំពីការលំអៀងដោយសមហេតុផល។[7]
>
> យុត្តិសាស្ត្រនេះ ត្រូវបានអនុវត្តជាទូទៅដោយតុលាការអន្តរជាតិ។

២១. អ្នកកត់សម្គាល់ដ៏សមហេតុផលក្នុងការការវាយតម្លៃអំពីភាពលំអៀងនេះគឺត្រូវតែជា"បុគ្គលម្នាក់ដែលមានព័ត៌មានគ្រប់គ្រាន់យល់ដឹងពីគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពមិនលំអៀងដែលបង្កើតបានជាផ្នែកមួយនៃមូលដ្ឋាន និងការវាយតម្លៃអំពីអង្គហេតុផងដែលថា ភាពអនាគតិ គឺជាករណីយកិច្ចមួយក្នុងចំណោមករណីកិច្ចផ្សេងទៀត ដែលចៅក្រមគ្រប់រូបត្រូវតែសច្ចាថាគាំទ្រលើកតម្កើនឡើង"។[8]

---

[7] សាលដីកាសាលាឧទ្ធរណ៍លើករណី Furundzija ទំព័រ ១៨៩

[8] ព្រះរាជអាជ្ញា តទល់នឹង Furundzija, IT-95-17/1-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី២១ ខែ កក្កដា ឆ្នាំ ២០០០ កថាខ័ណ្ឌ ១៩០

00163174





## IV. ការពិចារណាលើពាក្យបណ្តឹង

២២. អង្គបុរេជំនុំជម្រះធ្វើការពិភាក្សាលើបញ្ហាចោទប្រកាន់២ ដូចខាងក្រោម:

### i. មុខតំណែងរបស់លោកចៅក្រម នំយ ថុល ជាមន្ត្រីកងយុទ្ធពលខេមរៈភូមិន្ទ

២៣. មេធាវីលើកឡើងថា "ក្នុងឋានៈជាមន្ត្រីកងយុទ្ធពលខេមរភូមិន្ទ លោកចៅក្រម **នំយ ថុល** "ត្រូវស្ថិតនៅក្រោមបទបញ្ជានិងការវាយតម្លៃរបស់យោធា" និង" ស្ថិតនៅក្នុងជួរកងទ័ពដែលត្រូវស្តាប់បញ្ជាពីស្ថាប័ននីតិប្រតិបត្តិ" ក្នុងករណីនេះ គឺនាយករដ្ឋមន្ត្រីមកខាងពីគណបក្សប្រជាជនកម្ពុជា។"

២៤. អង្គបុរេជំនុំជម្រះពិចារណាឃើញថា លោកចៅក្រម **នំយ ថុល** មិនកាន់មុខតំណែងជាចៅក្រមក្នុងអង្គបុរេជំនុំជម្រះក្នុងឋានៈជាមន្ត្រីកងយុទ្ធពលខេមរភូមិន្ទទេ ប៉ុន្តែក្នុងឋានៈជាជនស៊ីវិល។ លោកចៅក្រម **នំយ ថុល** បានត្រូវតែងតាំង ដោយយោងតាមមាត្រា ៣.៣ និងមាត្រា៧.២ នៃកិច្ចព្រមព្រៀង និងមាត្រា១០ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

២៥. អង្គបុរេជំនុំជម្រះយល់ឃើញថា ការប្រៀបធៀបធ្វើឡើងដោយមេធាវីការពារក្តីជាមួយនឹងរឿងក្តីអូកាឡង់(Ocalan) នៅឯតុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប គឺមិនមានការពាក់ព័ន្ធគ្នាទេ ។ ចៅក្រមយោធាក្នុងតុលាការសន្តិសុខជាតិតួគី ក្នុងរឿងក្តីអូកាឡង់ គឺបំពេញមុខងារក្នុងឋានៈជាមន្ត្រីយោធា និងមិនមែនក្នុងឋានៈជាជនស៊ីវិល និង សមត្ថភាពផ្ទាល់ខ្លួនទេ។

២៦. ភស្តុតាងដែលបានលើកឡើងដោយមេធាវីការពារក្តីអំពីមុខតំណែងរបស់លោកចៅក្រម **នំយ ថុល** ជាប្រធានតុលាការយោធា និងការសន្និដ្ឋានដែលទាញចេញពីមុខតំណែងនេះ មិនឆ្លើយតបទៅនឹងភាពរឹងមាំនៃភស្តុតាងដែលតម្រូវ ដើម្បីជំទាស់ទៅនឹងការសន្មត់ទុកជាមុននៃភាពមិនលំអៀងឡើយ។

### ii. ការចូលរួមរបស់លោកចៅក្រម នំយ ថុល ក្នុងរឿងក្តីនយោបាយ

00163175

C11/29



២៧. មេធាវីបានលើកឡើងក្នុងពាក្យបណ្តឹងរបស់ខ្លួន កឋាខ័ណ្ឌ ២៨ ថា "លោកចៅក្រម **ន៉ី ថុល** បានបង្ហាញឱ្យឃើញនូវឆន្ទៈក្នុងការប្រើប្រាស់អំណាចតុលាការដោយមិនត្រឹមត្រូវ ដើម្បីបម្រើគោលនយោបាយរបស់គណៈបក្សប្រជាជនកម្ពុជា។ តួនាទីរបស់គាត់ ជាពិសេសនៅក្នុងរឿងក្តីចំនួន៣ បង្ហាញឱ្យឃើញយ៉ាងច្បាស់ថា គាត់ដាក់ដោយសេរីនូវបទដ្ឋានច្បាប់ជាមូលដ្ឋាននានានៅក្រោមការពិចារណានៃកាលានុវត្តន៍ភាពនយោបាយ"។ បន្ទាប់មក មេធាវីធ្វើការពិភាក្សាលើរឿងក្តីនយោបាយចំនួន ៣ ដែលលោកចៅក្រម **ន៉ី ថុល** បានចូលរួម និងបង្ហាញភស្តុតាងរបាយការណ៍មួយចំនួនពាក់ព័ន្ធទៅនឹងភាពមិនត្រឹមត្រូវនៃសវនាការទាំងនោះ និងចោទប្រកាន់ថាស្ថិតនៅក្រោមឥទ្ធិពលរបស់គណបក្សប្រជាជនកម្ពុជា ។ មេធាវីបានអះអាងថា លោកចៅក្រម **ន៉ី ថុល** គឺជាសមាជិកម្នាក់របស់គណបក្សប្រជាជនកម្ពុជា។

២៨. អង្គបុរេជំនុំជម្រះយល់ឃើញអំពីការពិតថា ចៅក្រមម្នាក់ដែលជាសមាជិកមួយរូបរបស់គណបក្សនយោបាយ មិនអាចយកមកធ្វើការសន្និដ្ឋានដ៏សំខាន់ណាមួយដែលថាការសម្រេចចិត្តរបស់គាត់គឺធ្វើឡើងដោយការលើកទឹកចិត្ត ឬក្រោមឥទ្ធិពលផ្នែកនយោបាយឡើយ។ នៅពេលដែលចៅក្រមម្នាក់បានស្បថចូលកាន់តំណែង គឺមានការសន្មតថាគាត់អាច ហើយនិងធ្វើការកែតម្រូវចិត្តរបស់គាត់ មិនឱ្យមានជាប់ពាក់ព័ន្ធទៅនិងជំនឿផ្ទាល់ខ្លួន ឬភាពលំអៀងណាមួយឡើយ។

២៩. អង្គបុរេជំនុំជម្រះកត់សម្គាល់លើសារណាតបរបស់លោកចៅក្រម **ន៉ី ថុល** ថាគាត់បានលាលែងពីសមាជិករបស់គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ក្រោយពេលរូបគាត់បានត្រូវតែងតាំង ។ ចំនុចនេះឆ្លើយតបទៅនឹងករណីខាងលើ។ ឯកសារយោងស្តីពីការទទួលយកពាក្យលាឈប់របស់គាត់ត្រូវបានភ្ជាប់មកជាមួយ ហើយពាក្យសុំលាលែងរបស់លោកចៅក្រម **ន៉ី ថុល** នេះត្រូវបានអនុម័តទទួលយក កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៦។

៣០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបី អ.វ.ត.ក ជាផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជាក៏ដោយ ក៏ អ.វ.ត.ក គឺជាតុលាការមួយដាច់ដោយឡែក និងឯករាជ្យ គ្មានការជាប់ពាក់ព័ន្ធជាមួយតុលាការផ្សេងទៀតនៅកម្ពុជាទេ។ ចៅក្រមនៅក្នុង អ.វ.ត.ក បានត្រូវជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

ដែលមានការឯកភាពជាអន្តរជាតិ និងបានធ្វើសច្ចាប្រណិធានដាច់ដោយឡែក និងផ្សេងពីតុលាការដទៃទៀត។ ក្នុងបរិបទនេះ អ.វ.ត.ក គឺជាតុលាការអន្តរជាតិថ្មីមួយដែលអនុវត្តបទដ្ឋាននិងនិយាមអន្តរជាតិ។

៣១. លើសពីនេះទៅទៀត មេធាវីការពារក្តីមិនបានយោងទៅដល់មូលដ្ឋានសំអាងផ្លូវច្បាប់ណាមួយនៃសំណើដែលថាការវិភាគចំពោះចៅក្រមក្នុងរឿងក្តីផ្សេងៗគ្នា អាចសន្និដ្ឋានថាមានការលំអៀងក្នុងរឿងក្តីដែលកំពុងដោះស្រាយនោះទេ ។ មេធាវីមិនបានបង្ហាញឲ្យឃើញថា គំនិតយោបល់ដែលស្តែងចេញក្នុងរឿងក្តីមួយ អាចនាំឲ្យកើតមាននូវភាពលំអៀងតាមរូបភាពខាងក្រៅនៅក្នុងរឿងក្តីមួយទៀតនោះទេ ។ វាក៏ជាការកត់សំគាល់ដ៏សំខាន់មួយដែលថា នួន ជា មិនត្រូវបានគេលើកឡើងថាមានជាប់ពាក់ព័ន្ធ ឬត្រូវបានលើកយកមកពិចារណាដោយចៅក្រម **ន៉ីយ ថុល** ក្នុងរឿងក្តីមុនឡើយ ។

៣២. ភស្តុតាងភាគច្រើនដែលបង្កើតឡើងដោយមេធាវីការពារក្តី គឺជាឯកសារអត្ថាធិប្បាយរបស់ភាគីទីបី និងពាក់ព័ន្ធជាទូទៅលើការកាត់សំគាល់ស្តីពីការចោទប្រកាន់អំពីសមត្ថកិច្ច និងហេតុផលដែលជំរុញទឹកចិត្ត នៃតុលាការកម្ពុជាទាំងមូលតែម្តង និងមិនមែនតែចំពោះតែលោកចៅក្រម **ន៉ីយ ថុល** ម្នាក់ប៉ុណ្ណោះទេ ។ ការកត់សំគាល់លើជាទូទៅ និងការអះអាងនេះ គឺគ្មានភស្តុតាងបញ្ជាក់អំពីភាពលំអៀងរបស់ លោកចៅក្រម **ន៉ីយ ថុល** ក្នុងរឿងក្តីលោក នួន ជា ទេ ។

៣៣. គ្មានភស្តុតាងណាមួយដែលបានលើកឡើងដោយមេធាវីការពារក្តី ដែលបង្ហាញឲ្យឃើញថា លោកចៅក្រម **ន៉ីយ ថុល** បានទទួលការណែនាំពីគណបក្សនយោបាយ ឬ បង្ហាញថាគាត់បានបំពេញភារកិច្ចតាមការបង្គាប់បញ្ជាពីគណបក្សប្រជាជនកម្ពុជា ឬពីបុគ្គលណាម្នាក់ផ្សេងទៀតឡើយ ។

៣៤. ដោយពិចារណាអំពីចំណុចជាមូលដ្ឋានជាច្រើនទៀត ដែលត្រូវបំពេញដោយមេធាវីការពារក្តី គុណភាពនៃភស្តុតាងដែលបានដាក់ជូនមក មិនឆ្លើយតបទៅនឹងបទដ្ឋានដែលនាំឲ្យមានការសន្និដ្ឋានថា លោកចៅក្រម **ន៉ីយ ថុល** បានបំពេញភារកិច្ចតាមការណែនាំរបស់ស្ថាប័ននយោបាយណាមួយ ឬថាគាត់ត្រូវបានលើកទឹកចិត្តដោយហេតុផលនយោបាយណាមួយឡើយ ។ ពុំមានការយល់ដឹងពីភាពលំអៀងដោយការកត់សម្គាល់ដែលបានដឹងអំពីព័ត៌មាន អំពីគ្រប់កាលៈទេសៈទាំងអស់ដែលពាក់ព័ន្ធ នៃបញ្ហាដែលបានដាក់មកចំពោះមុខអង្គបុរេជំនុំជម្រះឡើយ។

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C. ១១

00163177

C11/29

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០១)

## V. សន្និដ្ឋាន

យោងលើហេតុផលដូចបានបញ្ជាក់ជូនខាងលើ អង្គបុរេជំនុំជម្រះ សម្រេចជាឯកច្ឆន្ទថា:

១) ពាក្យបណ្តឹង មានផ្នែកខ្លះដែលមិនអាចទទួលយកបាន ដូចមានមូលហេតុដែលបានលើកឡើងក្នុងកថាខ័ណ្ឌ ៩ និង ១១ ខាងលើ និង

២) បដិសេធចោលពាក្យបណ្តឹងនេះ ។

សេចក្តីសម្រេច មិនបើកផ្លូវប្តឹងឧទ្ធរណ៍ទេ ។

**ធ្វើឡើងដោយអង្គបុរេជំនុំជម្រះ**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០០៨ ៧

**ចៅក្រមអង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING ម៉ែន ពេជ្ជសាលី Katinka LAHUIS ហ៊ុត វុធី ប្រាក់ គឹមសាន



ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh